00316281

ឯកសារ/លេខ: D164

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 04 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA.Ly

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| បញ្ជូនទៅ: | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទនៃការបញ្ជូន | ថ្ងៃទី២០ ខែ មេសា ឆ្នាំ២០០៩ |
| ភាគីដាក់ឯកសារ: | មេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ, លោក នួន ជា និង លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស (ឯកសារដើម) ~~ភាសាខ្មែរ~~ (អត្ថបទបកប្រែ) |
| ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: | សាធារណៈ: សម្ងាត់ CONFIDENTIAL CONFIDENTIEL 21/4/2009 |

**សំណើរួមជាបន្ទាន់របស់មេធាវីការពារ ស្នើសុំអោយបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុក ដែលផ្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("SMD")**

សាធារណៈ PUBLIC 23/06/2009

<u>ដាក់ឯកសារដោយ៖</u>

សហមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ
លោកមេធាវី ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

សហមេធាវីការពារក្តីលោក នួន ជា
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE

សហមេធាវីការពារក្តីលោក អៀង សារី
លោក អាង ឧត្តម
លោក Michael G. KARNAVAS

<u>ចែកចាយជូន៖</u>

សហចៅក្រមស៊ើបអង្កេត
លោក យូ ប៊ុនឡេង
លោក Marcel LEMOND

សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Robert PETIT

មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 24 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Ly

## I. សេចក្ដីផ្ដើម

1. អនុលោមទៅតាមវិធាន ៥៥(១០) មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ, លោក អៀង សារី និង លោក នួន ជា សូមដាក់សំណើនេះជូនសហចៅក្រមស៊ើបអង្កេត (ហៅថា "ក.ស.ច.ស") ស្នើសុំអោយបំពេញកិច្ចស៊ើបសួរដូចខាងក្រោមនេះ។ វាអាចជាការសមហេតុផលដើម្បីសន្និដ្ឋានតាមរយៈចរិតលក្ខណៈរបស់ឯកសារនានា ដែលផ្ដល់ដោយការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") ដាក់ចូលទៅក្នុង "ឃ្លាំងផ្ទុកឯកសាររួម" (ហៅថា "SMD") គឺមានផ្ទុកនូវភស្តុតាងដោះបន្ទុកផងដែរ។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីស្នើសុំសហចៅក្រមស៊ើបអង្កេត វិភាគលើឯកសារទាំងនេះស្របតាមភារៈកិច្ចរបស់ខ្លួន ដើម្បីកំណត់ភស្តុតាងដោះបន្ទុកដែលមានសក្ដានុពល។

## II. អង្គហេតុពាក់ព័ន្ធ

2. នៅឆ្នាំ ២00៧ ក.ស.ច.ស និង ក.ស.ព បានបង្ហាញដល់ភាគីនានានូវកម្រងឯកសារផ្ទុកក្នុង SMD ហើយដែលអាចស្រាវជ្រាវរកបានតាមរយៈគេហទំព័រនៅ អ.វ.ត.ក ECCC ZyIMAGE Search Portal[1] ។ យោងតាមពិធីសារស្ដីពី SMD[2] ឯកសារទាំងនេះគឺ:

> មិនទាន់ត្រូវបានធ្វើវិភាគដើម្បីរកអត្ថប្រយោជន៍ដាក់ក្នុងសំណុំរឿង [...] នៅឡើយទេ ។ ប៉ុន្ដែឯកសារមួយចំនួនអាចមានផ្ទុកនូវភស្តុតាងដោះបន្ទុក/ដាក់បន្ទុកពាក់ព័ន្ធ ហើយប្រភពរបស់ភស្តុតាងទាំងនោះ បានបើកចំហរួចមកហើយ ("Swedish Collection", DC-Cam និង មជ្ឈមណ្ឌលបូផាណា ។ល។)

3. មកដល់បច្ចុប្បន្ននេះ មានឯកសារដ៏ច្រើនលើសលុបត្រូវបានដាក់នៅក្នុង SMD ។ ជាពិសេស មានឯកសារ ១៧,៨០៧ ឯកសារត្រូវបាន "ចែករំលែក" ដោយ ក.ស.ព ។ អនុលោមតាម ក.ស.ព ឯកសារទាំងនេះអាចផ្ទុកនូវព័ត៌មានពាក់ព័ន្ធ រួមមាន៖
   - ព័ត៌មានស្ដីពីរចនាសម្ព័ន្ធ និង អង្គការលេខរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

---

[1] សូមកត់សំគាល់ថា មកដល់បច្ចុប្បន្ននេះ ទិន្នន័យនេះត្រូវបានគេប្រើប្រាស់សម្រាប់តែគោលបំណងដែលអនុញ្ញាតឲ្យភាគីអាចពិនិត្យមើលសំណុំរឿងជាផ្លូវការនៅក្នុងទម្រង់អេឡិចត្រូនិកតែប៉ុណ្ណោះ ។

[2] សូមមើល http://zylab/Ecel/ZyNET.exe?Client= Commom+Collection&Init=1&ZyAction=ZyActionr.។

- ភស្តុតាងពីការផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័ននានានៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។
- ការស្តាប់ចម្លើយជនរងគ្រោះ និង សាក្សីសំខាន់ៗ ។
- សេចក្តីថ្លែងដោយ/ការយកចម្លើយពីជនសង្ស័យនានាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ។
- ពត៌មានដែលរាយការណ៍អំពីស្ថានភាពនៅកម្ពុជាពីដើមទសវត្សឆ្នាំ ១៩៧០ និង ឆ្នាំ ១៩៨០ និង
- ការបោះពុម្ពផ្សាយជាផ្លូវការដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ[3] ។

4. នៅក្នុងកិច្ចប្រជុំរវាងតំណាងរបស់ ក.ស.ច.ស, ក.ស.ព និងអង្គភាពគាំពារការការពារក្តី កាលពីថ្ងៃទី៤ ខែ កុម្ភៈ ឆ្នាំ ២00៩[4] មានការលេចឮថា ក.ស.ព បានទទួលឯកសារទាំងនេះនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបអង្កេតបឋមរបស់ខ្លួន ហើយថាពួកគេពុំមានពេលវេលាដើម្បីវិភាគលើឯកសារទាំងនេះ នៅមុនពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យទៅស៊ើបសួររបស់ខ្លួននោះឡើយ។ ដោយសារតែ ក.ស.ព មិនចង់ឲ្យគេចោទប្រកាន់ពីការលាក់កំបាំងនូវធាតុផ្សំនៃភស្តុតាងដោះបន្ទុក និង ដោយសារតែពួកគេយល់ឃើញថា ឯកសារទាំងនេះអាចពាក់ព័ន្ធជាមួយសំណុំរឿង ឥឡូវនេះពួកគេសម្រេចបង្ហាញឯកសារទាំងនេះដល់ចៅក្រម និង ភាគីទាំងអស់តាមរយៈបណ្តាញមួយផ្សេងពីសំណុំរឿង។ ទោះបីជា ក.ស.ព មិនបានដឹងអំពីអត្ថិភាពនៃភស្តុតាងដោះបន្ទុកជាក់លាក់ណាមួយក្នុងចំណោមឯកសាទាំងអស់នោះក៏ដោយ ក៏ ក.ស.ព បានបញ្ជាក់យ៉ាងច្បាស់ថា ពួកគេមិនអាចច្រានចោលនូវលទ្ធភាពដែលមានអត្ថិភាពនៃភស្តុតាងបែបនេះដែរ ។ វាប្រាកដណាស់ថាដោយសារតែមូលហេតុនេះទើប ក.ស.ព "លាតត្រដាង" នូវឯកសារទាំងនេះ ។

## III. ច្បាប់ពាក់ព័ន្ធ

### ៣.១ ការបំពេញកិច្ចស៊ើបសួរ

5. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (ហៅថា "វិធាន") បានគូសបញ្ជាក់យ៉ាងច្បាស់នូវកាតព្វកិច្ចនិងសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និង ភាគីនានានៅក្នុងការបំពេញកិច្ចស៊ើបសួររបស់តុលាការ ។ ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតមានចែងនៅក្នុងវិធាន ៥៥(៥) ដែលចែងថា:

---

[3] ព័ត៌មានផ្តល់ដោយ "ECCC ZyIMAGE Search Portal" នៅ http://zylab/Ecel/ZyNET.exe?Client=Commom+Collection&Init=1&ZyAction=ZyActionr.។

[4] តំណាងមកពីផ្នែកគាំពារការការពារក្តីព្រាងរបាយការណ៍នៃកិច្ចប្រជុំនេះ ។

ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត។ នៅគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបសួរត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះ ជាភស្តុតាងដាក់បន្ទុក ឬ ភស្តុតាងដោះបន្ទុកក៏ដោយ [...] ។

ផ្ទុយពីសហព្រះរាជអាជ្ញា ដែលគ្រាន់តែប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ក្នុងអំឡុងពេលកិច្ចស៊ើបអង្កេតបឋមរបស់ខ្លួន ដើម្បីកំណត់ថា តើឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានប្រព្រឹត្តដែរ ឬយ៉ាងណានោះ[5] សហចៅក្រមស៊ើបអង្កេតមានតួនាទីស្វែងរកការពិត និង ដើម្បីធានាថា រាល់ភស្តុតាងដោះបន្ទុកសមហេតុសមផលទាំងអស់ ត្រូវតែបានរុករក[6] ។

6. អនុលោមតាម ៥៥(១០) ភាគីទាំងអស់មានលទ្ធភាពស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ៖

នៅគ្រប់ពេលទាំងអស់នៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា, ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ថាចាំបាច់ដល់ការស៊ើបសួរ...។

7. វិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងចែងបន្ថែមទៀត:

នៅគ្រប់ពេលទាំងអស់នៃកិច្ចស៊ើបសួរ ជនត្រូវចោទ អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះដល់កន្លែងកើតហេតុ បង្គាប់ធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងដទៃទៀតក្នុងនាមខ្លួន [...] ។

[5] សូមមើលវិធាន ៥០(១) ។

[6] សូមមើលការពិពណ៌នាអំពីតួនាទីរបស់ចៅក្រមសើបង្កេតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំងនៅ Duverger, *Manuel des juges d'instruction*, I, 3[e] éd., 1862, p. 425, quoted in Chambon, Guéry, *Droit et pratique de l'instruction préparatoire*, 6[e] éd., 2007, p. 119, n[o] 31.12 :'*Dégagé de toute préoccupation autre que celle de parvenir à la manifestation de la vérité, soucieux de ne pas compromettre ni la vindicte publique ni le sort des prévenus, il relèvera avec une sollicitude égale les armes de l'accusation et les instruments de la défense ; en un mot, faisant ses premiers devoirs de l'impartialité et de l'amour de la justice, il instruira toujours à charge et à décharge.*'

8. នៅក្នុងលិខិតមួយផ្ញើទៅឱ្យសហមេធាវីរបស់លោក នួន ជា[7] សហចៅក្រមស៊ើបអង្កេតផ្តល់ការបកស្រាយអំពីការស៊ើបសួរក្រោមវិធាននេះដូចខាងក្រោម:

> អំណាចស៊ើបសួរនៅចំពោះមុខតុលាការនេះ ត្រូវបានប្រគល់ផ្តាច់មុខទៅឱ្យសហចៅក្រមឯករាជ្យទាំងពីររូប និង មិនប្រគល់ទៅឱ្យភាគីនោះទេ ។ ពុំមានបទបញ្ញត្តិច្បាប់ណាដែលអនុញ្ញាតឱ្យភាគីបំពេញកិច្ចស៊ើបសួរជំនួសមុខឱ្យសហចៅក្រមស៊ើបអង្កេតឡើយ ខណៈដែលប្រព័ន្ធនីតិវិធីដទៃទៀតប្រហែលជាអនុញ្ញាត ។ តាមការពិត ភាគីមានសិទ្ធិក្រោមវិធាន ៥៥(១០) និង ៥៨(៦) ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតដំណើរការស៊ើបសួរបាន...។ ហេតុដូច្នេះ សមត្ថភាពរបស់ភាគីត្រូវបានកម្រិតត្រឹមតែការស៊ើបសួរបឋមតែប៉ុណ្ណោះ ដោយសារតែចាំបាច់សម្រាប់ការអនុវត្តសិទ្ធិរបស់ពួកគេឱ្យមានប្រសិទ្ធភាព ដើម្បីស្នើសុំនូវកិច្ចស៊ើបសួរ ។

9. វិធានផ្ទៃក្នុងមិនបានកំណត់អត្ថន័យនៃ "សំណើសុំកិច្ចស៊ើបសួរ" ទេ ប៉ុន្តែ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ[8] (ហៅថា "សាលដីការបស់ អ.ប.ជ ទាក់ទងការបកប្រែ") អង្គបុរេជំនុំជម្រះបានផ្តល់នូវនិយមន័យបន្ថែម។ សាលដីកាបានយោងវិធាន ៥៥(៨)នៃវិធានផ្ទៃក្នុងដែលចែងថា ក្នុងការដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន សហចៅក្រមស៊ើបអង្កេត "អាចចាត់វិធានការស៊ើបសួរណាមួយដែលនាំទៅរកការបង្ហាញការពិត"[9] ។ អង្គបុរេជំនុំជម្រះបានលើកឡើងបន្ថែមទៀតថា "ដំណើរការលាតត្រដាងការពិត ចាំបាច់ត្រូវពាក់ព័ន្ធនឹងការប្រមូលព័ត៌មាន"[10] ។

10. អង្គបុរេជំនុំជម្រះសន្និដ្ឋានថា "សំណើសុំបំពេញកិច្ចស៊ើបសួរគួរត្រូវគេបកស្រាយថា ជាសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត [...] ក្នុងគោលបំណងប្រមូលព័ត៌មានដែលនាំដល់ការលាតត្រដាងការពិត"[11] ។

---

[7] ចម្លើយតបចំពោះលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែ ធ្នូ ២០០៧ ទាក់ទងនឹងកិច្ចស៊ើបសួរ ចុះថ្ងៃទី ១០ ខែ មករា ២០០៨ ឯកសារលេខ A110/II ។

[8] ឯកសារលេខ A190/II/9 ចុះថ្ងៃទី ២០ ខែ កុម្ភៈ ២០០៩ ។

[9] សាលដីការបស់ អ.ប.ជ ទាក់ទងការបកប្រែ កថាខណ្ឌ ១៩ ។

[10] សាលដីការបស់ អ.ប.ជ ទាក់ទងការបកប្រែ កថាខណ្ឌ ២០ ។

[11] សាលដីការបស់ អ.ប.ជ ទាក់ទងការបកប្រែ កថាខណ្ឌ ២៣ ។

00316286



## ៣.២ សំណុំរឿង

11. លក្ខណៈជាសារវ័ន្តនៃកិច្ចស៊ើបសួរនៅក្នុងប្រព័ន្ធនីតិវិធីដែលប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺថាការស៊ើបសួរនៅដំណាក់កាលមុនអង្គសេចក្តី ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ ដោយអនុលោមតាម វិធាន ៥៥(៦) ចែងថា:

> ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុនៃការស៊ើបសួរជាលាយលក្ខណ៍អក្សរ [...] ។

បន្ថែមពីលើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស៊ើបសួរ ឯកសារទាំងអស់ដែលដាក់ដោយភាគី រួមទាំងភស្តុតាងជាសម្ភារៈទាំងអស់ត្រូវដាក់នៅក្នុងសំណុំរឿង។ សំណុំរឿងគឺជាផ្លូវតែមួយគត់នៃការលាតត្រដាងឯកសារ ដើម្បីឱ្យភាគីអាចពិនិត្យមើលបាន ។

12. ចំពោះដំណាក់កាលស៊ើបអង្កេតបឋម បើទោះបីវិធានផ្ទៃក្នុងមិនមានបទបញ្ញត្តិពាក់ព័ន្ធណាមួយចំពោះវិធានដែលលើកឡើងខាងលើក៏ដោយ ក៏វិធាន ៥៣(២) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចែងនូវសេចក្តីណែនាំដូចខាងក្រោម:

> ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវអមជាមួយសំណុំរឿង និង សម្ភារៈដទៃទៀតដែលបានចាត់ទុកជាភស្តុតាង ដែលសហព្រះរាជអាជ្ញាមាន រួមមានអ្វីទាំងអស់ដែលសហព្រះរាជអាជ្ញាបានដឹងថា អាចជាភស្តុតាងដោះបន្ទុកផងដែរ ។

វាច្បាស់ណាស់ថា សហព្រះរាជអាជ្ញាក៏បានរក្សាទុកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបអង្កេតបឋមរបស់ខ្លួន នៅក្នុងសំណុំរឿងផងដែរ ។ បន្ទាប់មក ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ព្រមជាមួយកំណត់ហេតុជាលាយលក្ខណ៍អក្សរ ត្រូវបានដាក់ទៅក្នុងសំណុំរឿងដែលរក្សាដោយ ក.ស.ច.ស ។

13. សហព្រះរាជអាជ្ញាមានកាតព្វកិច្ចនៅដំណាក់កាលស៊ើបសួរ លាតត្រដាងភស្តុតាងដោះបន្ទុកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដូចដែលបានចែងនៅក្នុងវិធាន ៥៣(៤) ថា:

> ក្នុងរយៈពេលឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេតនូវសម្ភារៈទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាច

នាំឱ្យគ្មានពិរុទ្ធភាព ឬ សម្រាលពិរុទ្ធភាពរបស់ជនសង្ស័យ ឬ ជនត្រូវចោទ ឬ ធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុតាងក្នុងការចោទប្រកាន់ ។

ដូចបានលើកឡើងពីខាងលើរួចមកហើយ ការបង្ហាញភស្តុតាងត្រូវតែដាក់នៅក្នុងសំណុំរឿង ។ ពុំមានបទបញ្ញត្តិផ្សេងនៅក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងការលាតត្រដាងភស្តុតាង ឬ សម្ភារៈដោយសហព្រះរាជអាជ្ញាឡើយ រួមទាំងការលាតត្រដាងភស្តុតាងក្រៅសំណុំរឿងផងដែរ ។

## IV. អំណះអំណាង

### ៤.១ SMD បានផ្លាស់ប្តូរបន្ទុកនៃការបង្ហាញភស្តុតាងមកលើមេធាវីការពារដោយមិនត្រឹមត្រូវ

14. **SMD** ត្រូវបានបង្កើតនៅខាងក្រៅវិសាលភាពនៃច្បាប់ដែលនៅជាធរមាន ។ តាមពិត វិធានផ្ទៃក្នុង មិនបានផ្តល់នូវច្រកណាមួយដើម្បីលាតត្រដាងភស្តុតាងណាមួយក្រៅតែពីសំណុំរឿងនោះទេ ។ **SMD** មិនស្ថិតនៅក្រោមវិធាន ៥៣(៤) នោះទេ ដោយសារវាអនុវត្តចំពោះភស្តុតាងដោះបន្ទុកដែលសហព្រះរាជអាជ្ញាបានដឹងតែប៉ុណ្ណោះ ។ នៅគ្រប់ករណីទាំងអស់ ការលាតត្រដាងភស្តុតាងបែបនេះ ត្រូវតែដាក់នៅក្នុងសំណុំរឿង ។ ម្យ៉ាងវិញទៀត ទាំង ក.ស.ច.ស និង ក.ស.ព មិនបានគោរពតាមបទបញ្ញត្តិច្បាប់ ឬនីតិវិធីណាមួយឡើយ ហើយ SMD ទោះបីជាតាមមធ្យោបាយណាក៏ដោយ ក៏មិនអាចពិចារណាថា បានបំពេញគ្រប់គ្រាន់ ឬ ត្រឹមត្រូវនូវភារៈកិច្ចស្របច្បាប់នៃការបង្ហាញភស្តុតាងដែរ ។

15. សហព្រះរាជអាជ្ញាបានដាក់បង្ហាញ **SMD** ជូនដល់ភាគីនានានៃសំណុំរឿង ដោយប្រើប្រាស់យន្តការអេឡិចត្រូនិកដូចគ្នានឹងសំណុំរឿងដែរ ហើយដែលការធ្វើបែបនេះត្រូវបានជំរុញដោយក្តីកង្វល់ដែលត្រូវធានាថា សហព្រះរាជអាជ្ញាមិនលាក់កំបាំងភស្តុតាងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនពីភាគីដទៃនោះឡើយ ។ មេធាវីការពារមិនអាចមិនអើពើចំពោះអត្ថិភាពរបស់ **SMD** ដែលប្រហែលជាត្រូវបានបង្កើតឡើង "ដើម្បីកុំអោយជាបន្ទុកធ្ងន់ធ្ងរហួសហេតុមកលើសំណុំរឿង"[12]ប៉ុណ្ណោះ ប៉ុន្តែនៅក្នុងស្ថានភាពជាក់ស្តែង ជាការដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរ និងយ៉ាងអយុត្តិធម៌មកលើមេធាវីការពារ ដែលបន្ទុកនោះមេធាវីការពារពិតជាមិនអាចបំពេញបាននោះទេ ។ មេធាវី

[12] សូមមើលពិធីសារ SMD ។

ការពារត្រូវតែធានាថា រឿងក្តីរបស់ជនត្រូវចោទ មិនត្រូវអន្តរាយដោយសារការខកខានមិនបានប្រើប្រាស់ឯកសារដោះបន្ទុកដែលមាននោះឡើយ ។

16. មេធាវីការពារមានបន្ទុកយ៉ាងធំធេងរួចមកហើយ ដែលបង្កឡើងដោយការបង្ហាញឯកសារភស្តុតាងដែលមិនទាន់បកប្រែយ៉ាងសន្ធឹកសន្ធាប់ ដែលដាក់អមជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយមិនប្រាកដថា តើឯកសារភស្តុតាងមួយណាដែលព្រះរាជអាជ្ញានឹងប្រើប្រាស់នៅពេលសវនាការឡើយ ។ ឥឡូវនេះ មេធាវីការពារត្រូវបានគេអញ្ជើញឱ្យពិនិត្យមើលការចងក្រងនៃភស្តុតាងដ៏ច្រើនលើសលុបដើម្បីធានាថា ពុំមានភស្តុតាងដោះបន្ទុកណាមួយត្រូវបានបំភ្លេចចោលដោយ ក.ស.ព និង ក.ស.ច.ស ឡើយ ។ ការបង្កើត SMD នេះ បានជះឥទ្ធិពលអោយមានការ ផ្ទេរដោយមិនត្រឹមត្រូវនូវបន្ទុកនៃការស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុក ដោយយកចេញពីភាគីដែលមានកាតព្វកិច្ចស៊ើបសួរតាមផ្លូវច្បាប់ មកដាក់លើមេធាវីការពារទៅវិញ ។

## ៤.២ សហចៅក្រមស៊ើបអង្កេតមានភារកិច្ចពិនិត្យ SMD ឡើងវិញ

17. សហព្រះរាជអាជ្ញា អះអាងថា ឯកសារ "ដែលបានចែករំលែក" អាចពាក់ព័ន្ធជាមួយសំណុំរឿង ហើយអាចរួមបញ្ចូលទាំងឯកសារដែលមានតម្លៃជាភស្តុតាងទៀតផង ។ ដោយសារការចង្អុលបង្ហាញលំអិតទៅកាន់ប្រភេទឯកសារដែលអាចមានក្នុងការចងក្រងនេះ អាចអោយគេសន្និដ្ឋានថា ឯកសារទាំងនេះអាចមានជាប់ពាក់ព័ន្ធពិតប្រាកដមែន ។ បន្ថែមពីលើនេះ ការទទួចរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងចរិតលក្ខណៈនៃឯកសារមួយចំនួនដែលជាភស្តុតាងដោះបន្ទុកដ៏មានសក្តានុពល មិនអាចមិនអើពើបានឡើយ ហើយត្រូវតែបានគេស៊ើបអង្កេតដើម្បីស្វែងរកការពិត ។

18. ដូចដែលបានចង្អុលបង្ហាញដោយអង្គបុរេជំនុំជម្រះ "សំណើសុំបំពេញកិច្ចស៊ើបសួរត្រូវតែបានបកស្រាយថា ជាសំណើសុំឱ្យបំពេញកិច្ចណាមួយដោយសហចៅក្រមស៊ើបអង្កេត [...] ក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត"[13] ។

[13] សាលដីការបស់ អ.ប.ជ ទាក់ទងការបកប្រែ កថាខណ្ឌ ២៣ ។

19. ផ្អែកលើព័ត៌មាននេះ មេធាវីការពារស្នើសុំដោយគោរពថា វាជាភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុង SMD ។ ការស៊ើបសួរមិនមែនគ្រាន់តែប្រមូលភស្តុតាង ឱ្យបានគ្រប់គ្រាន់ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនោះទេ ។ ការស៊ើបសួរមានគោលបំណងលាតត្រដាងការពិត ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតមានភារកិច្ចយ៉ាងច្បាស់ក្នុងការពិនិត្យមើលភស្តុតាងដោះបន្ទុក។ នេះជាមធ្យោបាយតែមួយគត់ ដើម្បីដោះស្រាយភាពមិនស្មើគ្នាយ៉ាង ច្បាស់ក្រឡែតដែលកំពុងគ្របដណ្តប់លើប្រព័ន្ធនីតិវិធីរបស់ អ.វ.ត.ក នៅដំណាក់កាលស៊ើបសួរ ព្រមទាំងស្ថានភាពអយុត្តិធម៌ ដែលបង្កឡើងដោយ SMD ។

## **៤.៣ ឯកសារនៅក្នុង SMD មិនត្រូវចាត់ទុកថា "អាចរកបាន" ដោយមេធាវីការពារក្តីឡើយ**

20. ម្យ៉ាងវិញទៀត មេធាវីការពារស្នើថា ដោយសារតែ SMD មានចំនួនច្រើនលើសលុប និងដោយសារធនធានដែលមេធាវីការពារមានស្រាប់មានកង្វះខាត នោះមិនអាចពិចារណាបានថា មេធាវីការពារ"អាចរកបាន"នៅពេលនេះ នូវឯកសារនៅក្នុង SMD តាមមធ្យោបាយច្បាស់លាស់ណាមួយ[14]បានឡើយ ។ ម្យ៉ាងវិញទៀត មេធាវីការពារសូមស្នើថា ខ្លួនត្រូវតែស្ថិតនៅក្នុងគោលជំហរមួយទទួលបានអត្ថប្រយោជន៍ពីភស្តុតាងដោះបន្ទុកណាមួយដែលអាចមាននៅក្នុង SMD នៅដំណាក់កាលជំនុំជម្រះ ឬ បណ្តឹងសាទុក្ខ ដែលមិនបានដាក់នៅក្នុងសំណុំរឿង ។ ដើម្បីធានាដំណើរការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ មេធាវីការពារត្រូវទទួលបាន និង ប្រើប្រាស់ភស្តុតាងដែលដោះបន្ទុក ។ តាមរយៈការប្រើប្រាស់ SMD ក.ស.ព និង ក.ស.ច.ស បានព្យាយាមគេចវេសពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ក្នុងការស្វែងរកភស្តុតាងដោះបន្ទុកដែលអាចជួយដល់ជនត្រូវចោទ ។ ការទទួលខុសត្រូវបែបនេះ មិនអាចថមថយ ឬ រលត់បាត់ឡើយ ទោះបីជាតាមវិធីណាក៏ដោយ ។ វាមិនមែនជាចម្លើយទៅនឹងការដែលអាចធ្វើឱ្យ SMD អាចប្រើប្រាស់បានដោយមេធាវីការពារនៅក្នុងកាលៈទេសៈមួយដែលតាមកម្លាំងកាយពិតជាមិនអាចធ្វើទៅបាន ចំពោះធនធានដែលមេធាវីការពារក្តីមានស្រាប់ ដើម្បីដំណើរការពិនិត្យឡើងវិញនូវឯកសារដែលមាននៅក្នុង SMD នេះ។

---

[14] មេធាវីការពារយោងវិធាន ៨៧(៤) ដែលចែងថា សំណើសុំបញ្ចូលភស្តុតាងថ្មី ត្រូវតែធ្វើឱ្យអង្គបុរេជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលស្នើសុំបញ្ចូលនោះ ពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ" និង យោងវិធាន ១០៨(៧) ដែលចែងថា ភាគីអាចស្នើបន្ថែមភស្តុតាងទៅអង្គជំនុំជម្រះតុលាការកំពូល បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ។

00316290



V. **ភាពបន្ទាន់នៃសំណើ**

21. មេធាវីការពារក្តីចាត់ទុកសំណើនេះ ជារឿង "បន្ទាន់" ដោយសំអាងលើមូលហេតុដូចខាងក្រោម ។

22. ប្រសិនបើ ក.ស.ច.ស បដិសេធសំណើនេះ នោះមេធាវីការពារក្តីនឹងចំណាយពេលវេលា និងធនធានដ៏ច្រើន ដើម្បីវិភាគឯកសារបន្ថែមរាប់ពាន់សន្លឹកនេះ ។ វានឹងតម្រូវឲ្យបែងចែកពេលវេលា និង ធនធាន ឡើងវិញដើម្បីមានលទ្ធភាពធ្វើការវិភាគនេះ ព្រមទាំងធនធានបន្ថែមទៀតឲ្យច្រើនជាងធនធានដែលមេធាវីការពារក្តីមាននៅពេលបច្ចុប្បន្ននេះ ។ ប្រសិនបើ ក.ស.ច.ស សម្រេចលើបញ្ហានេះនៅពេលចុងបញ្ចប់នៃដំណាក់កាលស៊ើបសួរដែលអនុញ្ញាតដោយច្បាប់ នោះមេធាវីការពារនឹងត្រូវបង្ខំចិត្តពិនិត្យមើលឯកសារទាំងអស់ដែលនៅក្នុង **SMD** ឬប្រថុយចូលរួមសវនាការដោយគ្មានបានវិភាគឯកសារទាំងនោះ ហើយដែលនាំឲ្យបាត់បង់ឯកសារភស្តុតាងដោះបន្ទុក ។ ដោយពិចារណាលើសារៈសំខាន់នៃឯកសារដែលនិយាយពីខាងលើក្រុមមេធាវីនីមួយៗ បានចាត់ទុកវាជាអាទិភាព ។

23. ដោយសារមូលហេតុនេះ ទើបមេធាវីការពារក្តីសូមដាក់សំណើជាបន្ទាន់នេះ ។ ដោយហេតុថាពុំមានពេលវេលាកំណត់ណាមួយ សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មេធាវីការពារក្តីសូមស្នើថា ក.ស.ច.ស ចេញសេចក្តីបង្គាប់ទៅដល់ភាគីទាំងអស់ រួមទាំងកាលបរិច្ឆេទផុតកំណត់សម្រាប់សហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឆ្លើយតប ព្រមទាំង ស្នើសុំឲ្យ ក.ស.ច.ស សម្រេចលើបញ្ហានេះឲ្យបានឆាប់បំផុត តាមការគួរ ។

24. ដោយហេតុថា សំណើនេះលើកឡើងនូវបញ្ហាចំៗ ដោយមិនបានយោងនូវបញ្ហាផ្នែកច្បាប់ដែលមានលក្ខណៈស្មុគស្មាញនោះទេ ដូច្នេះទើបមេធាវីការពារក្តីសូមសំណូមពរថា សំណើនេះនឹងត្រូវសម្រេចនៅក្នុងរយៈពេលខ្លី ។ មេធាវីការពារក្តីសូមសំណូមពរ ការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើនេះឲ្យបានឆាប់បំផុតតាមការគួរ និងនៅក្នុងករណីណាក៏ដោយត្រូវសម្រេចលើសំណើនេះក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសហព្រះរាជអាជ្ញាដាក់ចម្លើយតបរបស់ខ្លួន។ ការខកខានមិនបានសម្រេចលើសំណើនេះនឹងជំរុញឲ្យមេធាវីការពារក្តីបកស្រាយថា ជាការបដិសេធសំណើសុំដោយសន្មតដោយ ក.ស.ច.ស ។

## IV. សំណូមពរ

25. **អាស្រ័យហេតុនេះ** មេធាវីការពារក្តី សូមស្នើសហចៅក្រមស៊ើបអង្កេតដូចខាងក្រោម:

១) ពិនិត្យឯកសារទាំងអស់ដែលដាក់នៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD) ដោយ ក.ស.ព ឬ ក.ស.ច.ស ។

២) បង្កើតរបាយការណ៍លំអិតអោយបានគ្រប់គ្រាន់ទាក់ទងនឹងការវិភាគរបស់ខ្លួន ឲ្យមេធាវីការពារដើម្បីធានាថា កិច្ចស៊ើបសួរដែលចាំបាច់ទាំងអស់ ត្រូវបានបំពេញដើម្បីកំណត់ភស្តុតាងដោះបន្ទុកដែលមានសក្តានុពលភាព ។

៣) ផ្តល់បញ្ជីភស្តុតាងដោះបន្ទុកដែលមាននៅក្នុង SMD ។

៤) ចេញសេចក្តីណែនាំស្តីពីការដាក់ឯកសារដល់ភាគី ដើម្បីឲ្យសំណើនេះអាចត្រូវបានដោះស្រាយនៅក្នុងពេលវេលាសមស្រប ដោយអនុញ្ញាតឲ្យមេធាវីការពារក្តីរៀបចំសំណុំរឿងរបស់ខ្លួនឲ្យបានត្រឹមត្រូវ និង បញ្ចៀសការពន្យារពេលនៅក្នុងដំណើរការនីតិវិធីដោយមិនត្រឹមត្រូវ ។

26. ម្យ៉ាងវិញទៀត មេធាវីការពារក្តីសូមរក្សាសិទ្ធិនៅដំណាក់កាលជំនុំជម្រះក្តី ឬពេលធ្វើបណ្តឹងសារទុក្ខពឹងផ្អែកលើឯកសារដោះបន្ទុកដែលមាននៅក្នុង SMD ហើយដែលមិនទាន់បានដាក់នៅក្នុងសំណុំរឿង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០០៩

| | | |
|---|---|---|
| លោក ផាត់ ពៅស៊ាង | លោក សុន អរុណ | លោក អាង ឧត្តម |
| កញ្ញា Diana ELLIS QC | លោក Michiel PESTMAN | លោក Michael G. KARNAVAS |
| **មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ** | លោក Victor KOPPE | **មេធាវីការពារក្តីលោក អៀង សារី** |
| | **មេធាវីការពារក្តីលោក នួន ជា** | |